WANotify.org/Khmer

# របៀបប្រព័ន្ធ WA NOTIFY ដំណើរការ

WA Notify (គឺជាប្រព័ន្ធជូនដំណឹងអំពីការឆ្លងជំងឺនៅក្នុងរដ្ឋវ៉ាស៊ីងតោន) វាជាប្រព័ន្ធមួយដ៏សំខាន់ដើម្បីជួយបញ្ឈប់ការរាលដាលជំងឺកូវីដ១៩ COVID-19 ។ ដូចគ្នានឹងការពាក់ម៉ាស់ ការរក្សាគម្លាត និងការចាក់វ៉ាក់សាំង WA Notify គឺជាវិធីដ៏ល្អមួយដើម្បីការពារសហគមន៍របស់យើង។

WA Notify ធ្វើការតាមរយៈស្មាតហ្វូនដោយមិនចែករំលែកព័ត៌មានផ្ទាល់ខ្លួន ប្រាប់អ្នកប្រើប្រាស់វាឱ្យដឹងប្រសិនបើពួកគេប្រហែលជាអាចឆ្លងកូវីដ១៩ COVID-19 ។ វាគឺជាការលាក់ការសម្ងាត់ទាំងស្រុង ហើយវាមិនដឹងថា អ្នកជានរណា ឬក៏តាមដានអ្នកឬទីកន្លែងដែលអ្នកទៅ។

ការសិក្សាបង្ហាញឱ្យឃើញថា បើមានមនុស្សប្រើប្រព័ន្ធជូនដំណឹងពីការឆ្លងជំងឺកាន់តែច្រើន ផលប្រយោជន៍ក៏មានកាន់តែច្រើនដែរ។ គំរូទិន្នន័យនៅក្នុងរដ្ឋវ៉ាស៊ីនតោនបង្ហាញថាសូម្បីតែមនុស្សមួយចំនួនតូចដែលប្រើ WA Notify នឹងអាចកាត់បន្ថយការឆ្លងជំងឺនិងការស្លាប់។

## សូមបញ្ចូល WA NOTIFY ទៅក្នុងទូរស័ព្ទរបស់អ្នក

**នៅលើទូរស័ព្ទ iPhone:**

1. ចូលទៅកាន់ការកំណត់
2. រំកិលចុះក្រោមទៅការជូនដំណឹងពីការឆ្លង
3. ចុច "បើកការជូនដំណឹងពីការឆ្លង"
4. ជ្រើសរើសសហរដ្ឋអាមេរិក
5. ជ្រើសរើសរដ្ឋវ៉ាស៊ីនតោន

**នៅលើទូរស័ព្ទ Android:**

1. ចូលទៅកាន់ Google Play Store
2. ស្វែងរក WA Exposure Notifications (ការជូនដំណឹងពីការឆ្លង WA) ដើម្បីងាយស្រួលស្វែងរកកម្មវិធី
3. ទាញយកកម្មវិធី Washington Exposure Notifications (ការជូនដំណឹងពីការឆ្លងនៅវ៉ាស៊ីនតោន)

## នៅពេលដែលអ្នកបានបញ្ចូល WA NOTIFY ចូលទៅក្នុងទូរស័ព្ទរបស់អ្នក

នេះជាវិធីដែលវាអាចជួយបង្ការការរីករាលដាលនៃជំងឺ COVID-19 ។

**1**



គ្រាំពេលមនុស្សពីរនាក់ប្រើ WA Notify នៅលើទូរស័ព្ទស្មាតហ្វូនរបស់ពួកគេ ពេលនៅជិតគ្នា, ទូរស័ព្ទរបស់ពួកគេផ្លាស់ប្ដូរលេខកូដដោយចៃដន្យតាមរយៈប៊្លូធូស។ លេខកូដទាំងនេះគឺជាលេខកូដអនាមិកទាំងស្រុង ដោយគ្មានការតាមដានទីតាំង ឬប្ដូរព័ត៌មានផ្ទាល់ខ្លួនទេ។

**2**




ប្រសិនបើលនរណាម្នាក់តេស្ដវិជ្ជមានកូវីដ-១៩ ដែលត្រូវបានបញ្ជាក់លទ្ធផលពីមន្ទីរពិសោធក្រសួងសុខភាពសាធារណៈ នឹងផ្ញើសារជូនពួកគេបញ្ជាក់ពីដំណឹងនេះនិងពត៌មាន។ ជាជម្រើស អ្នកប្រើប្រាស់ប្រព័ន្ធអាចស្នើសុំលេខកូដផ្ទៀងសម្រាប់ការធ្វើតេស្តវិជ្ជមាននៅផ្ទះ។

**3**



អ្នកដែលធ្វើតេស្តវិជ្ជមាន សូមចុចលើតណរភ្ជាប់ ឬចុចលើកន្លែងជូនដំណឹង រួចហើយធ្វើតាមគ្រប់ជំហានទាំងអស់ដើម្បីបញ្ជាក់លទ្ធផលនៅក្នុងកម្មវិធីអែប (**app**) ។

**4**



អ្នកប្រើប្រាស់ WA Notify នឹងទទួលដំណឹងថា ពួកគេប្រហែលជាអាចឆ្លងកូវីដ-១៩ COVID-19 ប្រសិនបើពួកគេនៅជិតបុគ្គលអនាមិកណាមួយដែលប្រើ WA Notify ដែរ ដែលទើបតែតេស្តវិជ្ជមានកូវីដ-១៩ COVID-19 នាពេលថ្មីនេះ។

**5**




ប្រព័ន្ធជូនដំណឹង មានតំណភ្ជាប់ទៅនឹងព័ត៌មានស្តីអំពីអ្វីដែលត្រូវធ្វើបន្ទាប់មកទៀត ដើម្បីការពារខ្លួនអ្នកនិងអ្នកដ៏ទៃ។ វាមិនប្រាប់អំពីព័ត៌មានស្តីពីអ្នកដែលបានធ្វើតេស្តវិជ្ជមាន ឬកន្លែងដែលការឆ្លងរោគអាចកើតឡើងនោះទេ។